ភ្នែកគេបោះបង់ចោលការសម្លឹងទៅជម្រៅភ្នែកស្រី ដែលបង្កប់នូវក្ដីភិតភ័យចង់សុំក្ដីមេត្តា។ ភាពក្បត់ចិត្តនិងកាចកោងរបស់នាង ឥន្ទ្រាទើបនឹងឃើញជាលើកដំបូងប៉ុននោះក្នុងចំណោមមនុស្សស្រីដែលគេជួប។

ស្រីៗដែលគេជួបទាំងនោះ ក្រៅពីជាឧបករណ៍បម្រើតណ្ហាមនុស្សប្រុស និងទន់ភ្លន់យកចិត្តយកថ្លើមគេ មានអ្វីផ្សេងទៅ? មនុស្សស្រីម្នាក់នេះ ក្រៅពីធ្វើទុក្ខបុកម្នេញគ្រួសារគេ ថែមទាំងបណ្ដាលឱ្យប្អូនប្រុសគេនៅស្រវឹងអទីនួដល់ថ្មើរណេះ សមទេនាងចង់បានការយល់ចិត្ត?

ស្រីនៅតស៊ូសម្លឹងមកពេញផ្ទៃមុខបុរសម្នាក់ដែលហាក់ដូចជាគេនេះមានចិត្តសែនស្ងប់ មិនងាយស្មានដឹងអារម្មណ៍។ រហូតគេស្គាល់ឈ្មោះ Fake ទាំងអស់របស់នាង បានជានាងត្រូវចាញ់វិញបន្តិចស្ងាត់មាត់ដូចគេចុក លបប្រើពេលពន្យារពិចារណាថា គេនេះមានបំណងអ្វី ហើយបានស៊ើបការណ៍ពីនាងច្រើនបែបនេះតាំងតែពីពេលណាមក?

ប្រុសរវេភ្នែកចេញមិនថ្លក់ការសម្លឹងជាមួយនាង ទេសកាលអឺមកទើរប៉ះនឹងដើមទ្រូងចំហ ដែលគេបានឃើញទាំងស្រុងមួយរយភាគរយនៅក្នុងបន្ទប់ទឹកកាលពីល្ងាច។

ពេលនេះនាងមានអាវទាញមកដើម្បីបិទបាំងខ្លះហើយ ប៉ុន្តែនៅតែចំហណាស់សម្រាប់គេនិងមនុស្សប្រុសៗលើកោះនេះ។

អាការៈប្ដូរពណ៌លើថ្ពាល់របស់គេ បណ្ដាលមាណវីយើងឱ្យដឹងភ្លាមថាគេកំពុងគិតពីរឿងអ្វី។ បេះដូង ចាប់ផ្ដើមលោតញាប់តាមចំណុចខ្សោយរបស់មនុស្សស្រី ដែលត្រូវមកនៅកណ្ដាលចំណោមមនុស្សប្រុសច្រើនគ្នា ហើយក្នុងសភាពបែបនេះ នៅក្នុងកាលៈទេសៈនេះ។ នីយ៉ាដឹងថា មិនអាចសំងំស្ងៀមទេព្រោះនាងត្រូវធ្វើអ្វីម្យ៉ាងទប់ស្កាត់រឿងដែលពួកគេកំពុងគិត៖

«ស្គាល់ខ្ញុំច្បាស់ល្អហើយ! បងប្រុសខ្ញុំជាប៉ូលិស! គាត់មិនលើកលែងឱ្យឯងទេ!»

បុរសនៅឱនមុខនៅឡើយ តែភ្នែកគេបើកមកធំជាងមុន សម្លឹងនាង។ មាត់គេចំហឡើងបន្តិចពេលឮនាងរំឭកពី«ឧត្តមសេនីយ៍ជេន» បបូរមាត់នរៈចរិតចម្លែកនេះ ហាក់ស្ទើរសើចស្ទើរមិនសើចបញ្ចេញធ្មេញគេទាំងជួរនៅបង្អើយក្បែរភ្នែកស្រីដែលតក់ស្លុត។

ស្មាធំៗរបស់គេរេតិចៗ ជំនួសឱ្យសម្ដីថា «ខ្លាចណាស់បងប្រុសនាង!» តែមាត់គេកម្របញ្ចេញសំឡេង បានជាតរុណីមិនឮពាក្យក្រអឺតដែលគេចង់សាបព្រួស។

«ឮអត់? លែងខ្ញុំទៅវិញភ្លាម នេះបើចេះគិត និងមិនចង់មានរឿង!»

នាងខំនិយាយ តែសំឡេងនីយ៉ាខ្សាវៗជាងមុនព្រោះចាញ់ច្រាបកែវភ្នែកមុតៗនៃបុរសចំពោះមុខ ។

គេនៅស្ងៀមស្នើ តែភ្នែកគេដូចជាមានមោទនភាពនិងសប្បាយចិត្តខ្លាំងនៅពេលដែលឮស្រីអួត និយាយអំពីបងប្រុសរបស់នាង។ ជាតិជាស្អប់រឿងនាងនិងសមាសភាពពាក់ព័ន្ធប៉ូលិសស្រាប់ ហើយ  នេះមិនទាន់រាប់ភាពក្បត់បេះដូងយូស៊ូក្នុងនាមជារនុកក្នុង «បង!.....បងឥន្ទ្រា.....ខ្ញុំស្លាប់ ហើយបង!.....ខ្ញុំកំពុងស្លាប់! បងឃើញទេ មនុស្សអន់ដូចខ្ញុំ! ស្រីបោកខ្ញុំណ៎ាបង! វាបោកបេះដូងប្អូន បងឯង!» ចុងក្រោយ ពាក្យដែលនាងដែលដៀលគេ«មនុស្សព្រៃ»។

គេដកថយ បែរមករកកូនចៅស្ដួរតិចៗស្របសព្ទសំឡេងស្រទន់របស់គេ៖

«ប្អូនប៉ូលិសណ៎ា បងគេធំផង! ខ្លាចទេ?»

ស្រីស្រស់ក្នុងចំណង រវេភ្នែកសម្លឹងកូនចៅគេម្នាក់ៗដែលបង្ហាញភាពគឃ្លើនមក បញ្ជាក់ចម្លើយ ស្រេចថា ព្រោះតែនាងជាប្អូនឧត្តមសេនីយ៍ជេនហ្នឹងហើយ នាងនឹងត្រូវធូន់មិនខានយប់នេះ។

ជាមួយនឹងទឹកមុខត្រជាក់ស្រិបងាកមករកនាងវិញ គេឃើញភ្នែកគ្រលួងៗមិនសុខចិត្តរបស់នាង ។ នាងខឹងណាស់ ព្រោះគ្មានមនុស្សរបស់គេណាម្នាក់តបឆ្លើយទេ។ ពីព្រោះមនុស្សស្ងប់ស្ងាត់ដូចជា កូនប្រុសច្បងរបស់ម្ចាស់កោះម្នាក់នេះ មិនត្រឹមតែមិនចូលចិត្តស្ដាប់យោបល់ ថែមទាំងមិនចូលចិត្ត និយាយច្រើនផង តើមានប្រយោជន៍អីដែលកូនចៅគេមកប្រថុយធ្វើថ្លើមធំ ទៅជូនយោបល់គេនៅ ពេលដែលឃើញស្រាប់ថាគេកំពុងខឹងខ្លាំងនោះ?

«មនុស្សកំសាក!!!!»

នាងថាតិចៗដាក់កែវភ្នែកគេ។ គេព្រេចភ្នែកដែលមុតថ្លានិងស្រទន់ដោយមោទនភាព។ នាង បន្ថែម៖

«ធ្វើបាបស្រី! អន់ណាស់លោកឯង!!»

បុរសដៀងភ្នែកសម្លឹងនាងដោយហួសចិត្ត។ ពិតមែនណ៎ា តាំងពីចេះដេកឱបស្រីមក មិនដែល ឃើញមនុស្សពូកែរកពាក្យមកជេរច្រើន ដូចម្នាក់នេះទេ។ គេសម្លឹងចន្ទនីយ៉ាពីលើដល់ក្រោម។ ភ្នែក មនុស្សស្រីម្នាក់នេះក្រឡង់ៗ ច្រមុះស្រួចខឹងក្រហម មាត់ពូកែដៀលដូចមិនចេះស្គាល់រាក់ជ្រៅខ្ពស់ ទាប មិនដឹងខ្លួនអាចត្រូវប្របាច់កស្លាប់តែត្រឹមប៉ុន្មានមាត់ទៀត នាងមិនខ្លាចអ្វីទាំងអស់ព្រោះ «អាង បង»?

ផ្កាស្រស់ស្អាតមួយទងនេះស្រាប់តែក្លាយជារឿងកំប្លែងសម្រាប់គេ។ មនុស្សស្រីដូចនាង រឹងរូសមិនស្មោះត្រង់ ថែមទាំងមិនសុភាព ម៉េចនឹងអាចធ្វើឱ្យបេះដូងមួយប្រឡាក់ប្រឡូសដោយឧក្រិដ្ឋនិងអំពើព្រហើនសព្វតែមុខនេះទោរទន់។ សមត្ថភាពរបស់នាងជះទឹកស្អុយមួយថូកណ្ដាលសណ្ឋាគារទំនើបចំកណ្ដាលមុខគេ មិនមែនស្រីណាក៏អាចធ្វើបាននោះទេ ពេលនេះមកដៀលគេថា «កំសាក» បានទៀត.....គេញឹមៗ នាងបន្ថែមខ្លីទៀត៖

«បានតែជាមួយមនុស្សក្នុងចំណង!»

«ស្រាយចំណង!»

គេបញ្ជាខ្លីបីម៉ាត់ ដោយប្រើភ្នែកត្រជាក់ល្ហឹមសម្លឹងឪនាង ខណៈពេលបេះដូងខាងស្រី បីដូចកំពុងត្រដរខ្យល់ មកត្រូវបានគេបើកចំហបញ្ចូលអុកស៊ីសែនឱ្យ ជាមួយបទបញ្ជាចុងក្រោយនៃប្រុសឈាមត្រជាក់។

នាងចង់សួរថា នាងហត់ពេកស្ដាប់ខុស ឬមួយកំពុងជិតស្លាប់នាងចេះស្រមៃ? តែចំពោះកូនចៅគេវិញ ឥន្ទ្រានិយាយតែបីម៉ាត់ប៉ុណ្ណោះ មិនបាច់និយាយច្រើនដងទេ។

មនុស្សរបស់គេពីរនាក់ស្ទុះចូលមកដល់ក្បែរនាង ធ្វើឱ្យនីយ៉ាងាកទៅសម្លឹងពួកគេត្មែរ ដោយសង្ស័យថាតាមពិតទៅ ពួកគេពិតជាស្រាយចំណងមែន ឬជាពាក្យដាក់ម៉ូគ្នាធ្វើបាបនាង?

មែន! ចំណងត្រូវបានស្រាយ នាងប្រញាប់រើរុះខណៈដៃទាំងសងនិងជើងហាក់ស្ពឹកៗ។

«ចង់ធ្វើម៉េចឥឡូវ?»

សំណួរបុរសមានអំណាចពោលសួរមកបន្ថែមស្របពេលគេរុញប្រាណខ្ពស់លលៃក្រោកឡើងមកចោលនាង។ ស្រីតូចផ្ទង់អារម្មណ៍ត្រលប់មកវិញដោយងើបមុខតាមសម្លឹងគេ។

ទាំងរាងកាយនៅមិនទាន់ក្រោកទាន់បុរសនេះនៅឡើយ នាងមិនចង់មានជំហរចាញ់គេទេ។ គេក្រោកឡើងបានមុនយ៉ាងស្រស់សង្ហា ហើយឈរបង្អួតកម្ពស់កំពរច្រងាងកាងចំពោះមុខនាង ជាមួយពន្លឺភ្នែកឪ ហើយសំណួរក៏ខែងរ៉ែង ម៉្លោះហើយនីយ៉ាឆ្លើយស្រួយៗ៖

«សាកគ្នា! មួយទល់នឹងមួយ!»

នាងនិយាយខ្លីៗ គ្រប់គ្នាហួសចិត្ត។ មនុស្សស្រីស្លៀកពាក់បែបនេះ មុខមាត់បែបនេះ មានសម្ដីព្រហើនដូចកូនប្រុសធ្លាប់តែលេងវាយតប់គ្នា?

មិនរវល់អ្នកណាគិតបែបណា ប្អូនស្រីប៉ូលិសដឹងតែចង់វាយតប់ជាមួយមនុស្សពាលម្នាក់នេះហើយ។ នាងនិយាយចប់ភ្លាម ខំច្រត់ដៃទាំងពីរយោងកាយ ក្រោកមកប្រឈមមុខនឹងជននេះ ប៉ុន្តែកដៃរបស់នាងដែលត្រូវចងយូរពេក វាស្ពឹកគ្មានកម្លាំង មិនអាចជួយនីយ៉ាឱ្យទប់ខ្លួនឯងបាន ក៏ផ្កាប់មុខមកលើឥដ្ឋទាំងជំហរវិញ។ ការណ៍នេះញ៉ាំងឱ្យនារីតូច ហាក់ដូចជាកំពុងក្រាបសំពះក្រោមបាតជើងបុរសនេះ ក្នុងសភាពខកចិត្តជាខ្លាំង ។ កំភួនដៃទាំងពីរត្រូវទើរផ្ទាល់ធរណី ប្រឡាក់ប្រឡូសយ៉ាងឈឺចិត្ត នៅក្រោមទឹកមុខអំនួតដែលបុរសនេះកំពុងបង្ហាញលើនាង។

«ក្រោកមក! ក្រោកឡើងឱ្យបានសិនមក បើនាងចង់តតាំងជាមួយគេ!» នាងថាឱ្យខ្លួនឯងក្នុងចិត្ត ហើយប្រវេប្រវាក្រោកឡើង ខណៈពេលដែលមនុស្សប្រុសនៅស្ងៀមតស៊ូរង់ចាំជាមួយទឹកមុខស្មើ។

ពួកមនុស្សអត់ចិត្តនេះ មិនដឹងកើតចេញមកពីកុលសម្ព័ន្ធណាទេ ចរិតគ្មានស្គាល់មនុស្សស្រី ឃើញមនុស្សដួលក្រាបក៏មិនបោះដៃមកយោងជួយគ្នា ចរិតនេះសមតែបងប្រុសមកវាយខ្នោះយកទៅប្រដៅសីលធម៌ខ្លះ។

នីយ៉ាគិតទាំងសៅហ្មង។ ពេលក្រោកមកទល់កម្ពស់ត្រឹមទ្រូងនាយ អ្នកណាមើលមិនឃើញ តែនាងឃើញស្នាមញញឹមបានចិត្ត ឌឺដង នៅក្នុងពន្លឺភ្នែកស្រទន់នៃមនុស្សប្រុសនេះ ទោះបីជាបបូរមាត់គេមិនកម្រើក។

«គ្រាន់តែតស៊ូជាមួយមនុស្សស្រីម្នាក់ ចាំលើកគ្នាមកកក្រើកគគ្រឹកគគ្រេងដែរ?»

នាងថាឱ្យកែវភ្នែកស្រទន់របស់គេ ពិតជាមានឥទ្ធិពលឱ្យគេព្រេចភ្នែកមមីរគិតបាន។ សម្រាប់ឥន្ទ្រា នាងចន្ទនីយ៉ានេះ មិនចេះខ្វះពាក្យនិយាយមែន  នាងមានទេពកោសល្យមួយដែលគេមិនឃើញមាន មិនចេះខ្វះពាក្យប្លែកៗមកនិយាយ ដែលឥន្ទ្រាគ្មានទេពកោសល្យនេះឡើយនៅក្នុងសំណុំខួរក្បាលគេ។

ប៉ុន្តែគេដូចជាចូលចិត្តស្តាប់នាងនិយាយណាស់។ ខាងប្រុសក្តាប់ដៃទាំងសងឈរយ៉ាងសង្ហាជាមួយការសម្លឹងស្មើៗ។  ទាំងទឹកមុខម៉ឺងម៉ាត់នាងក៏ចរចាបន្ថែម៖

«ខ្ញុំត្រូវការចេញពីកន្លែងនេះ!»

គេកម្រើកស្នាតិចៗ ជំនួសឱ្យការផ្ទុះសំណើចចំអក។ បបូរមាត់គេញឹមៗកាចៗដូចប្រាប់ថា លេងសើចមេះ?  ខណៈពេលដែលនាងពិតជាចង់ ស្តាប់ការសម្រេចចិត្តរបស់គេ។

«សាកគ្នាមួយទល់នឹងមួយមែនអត់ និយាយមុននេះ?» ប្រុសសួរមក។

គេគិតដល់រឿងវាយគ្នាឬក៏រឿងបាញ់បោះ? នីយ៉ាគិតផងរេមកសម្លឹងឃើញ ស្នាប់កាំភ្លើងខ្លីលៀនចេញពីក្នុងចង្កេះខោរបស់គេមនុស្សនេះ។ គេជាជនពាលពិតៗ ដែលនាងមិនធ្លាប់បានជួបឬឃើញនៅខាងក្រៅ ធ្លាប់តែឃើញក្នុងកុន។

«មើលមើល៍ ខ្ញុំស្ពឹកដៃស្ពឹកជើងត្រូវគេចងមករាប់ម៉ោង! បើសាកមួយទល់នឹងមួយ ស្មានខ្ញុំខ្លាច ប៉ុន្តែវាអយុត្តិធម៌ពេក!»

«ខ្ញុំមានអ្វីមួយយុត្តិធម៌សម្រាប់ មនុស្សដូចនាង!»

«ធ្វើយ៉ាងម៉េច?» នាងប្រញាប់សួរ តែខាងគេមិនតបនឹងសំណួរនេះ បែរជាផ្តើមនិយាយឡើង៖

«វត់ទៅ!»

នាងបើកភ្នែកគ្រលួងៗ«មិនយល់» គេនៅតែនិយាយបន្តទៅមុខ៖

«បើឱ្យចាប់បានវិញ លើកទីមួយ នឹងត្រូវអត់បាយក្រហាយទឹក បីថ្ងៃ បីយប់!»

ស្រីស្អាតឱបសាច់កំភួនដៃទាំងឈឺចុកចាប់ព្រោះស្ពឹកក្នុងចំណងយូរ។ ក្នុងចិត្តលបគិតភ្លាមៗ « អ្វី? គិតថាយើងឃ្លានបាយឯងណាស់?»។

សំឡេងប្រុសលាន់មកបន្ថែម៖

«ចាប់បានលើកទីពីរ...»

នាងខំប្រឹងផ្ទៀងស្តាប់....

«នឹងត្រូវចងព្យួរជើងឡើងលើ មួយយប់ទល់ភ្លឺ!»

ស្រីលើលេបទឹកមាត់ភ័យ ព្រោះភ្នែកគេមុតៗមិនដូចនិយាយលេងទេ។ ដៃទាំងសងរបស់នីយ៉ាទម្លាក់មកក្តាប់រ៉ូបពណ៌សស្តើងនេះជាប់ ចិត្តនាងលបលួចពិចារណា «ឈុតបែនេះ ចងជើងយើងព្យួរឡើងលើ ពេលនោះសំពត់នឹងធ្លាក់មកគ្របមុខរបស់យើង ហើយខ្លួនយើងនឹងអាក្រាតមែនទេប្រុសចង្រៃ»។

កំហឹងបញ្ចេញតាមកែវភ្នែកស្រីជាកំហឹងដែលធ្វើឱ្យគេសប្បាយចិត្ត។ ទាំងមួម៉ៅមាត់ខាំសង្រ្កឹតធ្មេញដាក់ជនពាលដែលនិយាយបន្ថែមរួៗ៖

«ឱកាសចុងក្រោយនៅលើកទីបីសម្រាប់ប្អូនប៉ូលិស.....»

នីយ៉ាមិនចង់ស្តាប់ទេ ពីព្រោះគិតថា ត្រឹមតែមួយលើកនេះនឹងរត់ចេញឱ្យបាត់សូន្យទៅហើយ ប៉ុន្តែគេនិយាយមកមិនឈប់ ទាំងសម្លឹងផ្តោតចំៗលើគ្រាប់ភ្នែកខឹងរបស់នាង....

«ឈ្លើយសឹកនឹងត្រូវទម្លាក់ចូលទៅក្នុងសមុទ្រ!»

ប្អូនប៉ូលិស ឈ្លើយសឹក សុទ្ធតែជាភាសាថ្មី តែស្រីភ្ញាក់ផ្អើលចាញ់ពាក្យ «ទម្លាក់ចូលទៅក្នុងសមុទ្រ»។ សំឡេងរលកសមុទ្រ? នឹកឃើញឡើងវិញមែន! កែវភ្នែករបស់នាងរេចុះឡើង។ ត្រូវហើយ ទីនេះគឺជាសមុទ្រ យើងរត់របៀបម៉េចទៅ?

អម្បាញ់មិញពិតជាឮរលកបោកច្រាំង អាល័យតែផ្តោតទៅលើមនុស្សព្រៃអស់នេះ យើងរិះនឹងភ្លេចថាទីនេះជាកន្លែងអីទៅហើយ?

មិនដែលទទេៗគេហ៊ានបណ្តោយឱ្យយើងរត់? គេអាងអីទៅ? អន្ទាក់?

នាងងើបមុខសម្លឹងជននេះសាជាថ្មី និយាយផងដែរ៖

«ខ្ញុំមានលក្ខខណ្ឌ!»

គេងាកមុខចេញ ជាសញ្ញាថា «មិនទទួលស្តាប់» ។

«គ្មានសិទ្ធិនិយាយលក្ខខណ្ឌទេប្អូនប៉ូលិស!»

«បើគ្មានលក្ខខណ្ឌឱ្យខ្ញុំរត់ម៉េចទៅ! មើលមើល៍ ស្បែកជើងខ្ញុំក៏គ្មាន! ខ្សែលើ!»

ប្រុសងាកមកវិញស្មារបស់គេក៏ងាកមកតាម ប្រហែលជាមកពីគេមិនដែលស្គាល់ពាក្យ«ខ្សែលើ» នេះ។ សារជាតិគេ ទំនងធំធាត់ឡើងមកនាតំបន់មួយរស់នៅឆ្ងាយពីភូមិករ ទីផ្សារពេក មិនដែលស្គាល់ឬចេះប្រើពាក្យច្រើនឱ្យដូចក្មេងធម្មតានិយាយនោះទេ នាងក៏ពន្យល់គេដោយមិនចាំបាច់ឮគេសួរ៖

«ខ្សែលើ បានន័យថា លោកឯងដឹងថា ខ្ញុំនឹងចាញ់លើគោកហើយ នៅតែដាក់ប្រស្នាមក! មនុស្សអីចឹងចេះតែមាននៅលើផែនដីនេះដែរ!»

គេផ្ទុះសំណើចរង្គើទ្រូង ដែលជាអាការៈគេកម្រនឹងបញ្ចេញមកណាស់។ សំណើចនេះទ្រាំមិនបាន មិនអាចបង្កប់លាក់ក្នុងដំណើរនៃចង្វាក់បេះដូង បានជាត្រូវទម្លាយចេញ។

ហើយបែរមកវិញលើកនេះ ព្រោះគេគិតថា មនុស្សស្រីម្នាក់នេះមានពាក្យជេរប្លែកៗបានជានិច្ច។ សូម្បីតែពាក្យដែលគេមិនធ្លាប់ឮ«ចេះតែមាននៅលើផែនដីនេះ»ក៏នាងនិយាយចេញមកបាន?

យ៉ាងហោចណាស់ នាងជាអ្នកបង្រៀនគេនូវពាក្យមួយចំនួនដែលប្លែកគួរឱ្យគ្រើត គួរឱ្យក្នាញ់....

«ចង់បានស្អី?» គេសួរឡើង។

«ស្បែកជើងកីឡាមួយគូ ខោអាវកីឡាមួយកំប្លេ!»

«គ្មានទាំងពីរ! លើកោះនេះគ្មានរបស់មនុស្សស្រីទេ!»

កោះ?

នាងចាប់ពាក្យគេហើយគិតទាំងភ្ញាក់ផ្អើល។

«ចាប់ផ្ដើមទៅ! រាប់ដល់ដប់!»

នីយ៉ាសម្លឹងមកគេវិញគ្មានពេលគិតពីរឿង«កោះ»ទៀតទេ។ មនុស្សនេះ ពេលវេលាដែលគេនិយាយលឿន ទើបនឹងស្គាល់គ្នាក៏នាងសម្គាល់ដឹងដែរថា អ្វីដែលគេនិយាយ តែងតែយកជាការ មិននិយាយពីរដង ហើយធ្វើសកម្មភាពលឿនបំផុត ដោយគ្មាននរណាអាចរារាំងគេបាននោះទេ។

ជនផ្ដាច់ការម្នាក់ដែលនៅចំពោះមុខនាង សូម្បីតែកូនចៅគេក៏«មិនហ៊ានក្អក»ចេញយោបល់ដែរ។

នាងខំងាកសម្លឹងគ្រប់គ្នាហើយរកអន្តរាគមៈ

«ឃើញអត់? គេមិនទទួលយកលក្ខខណ្ឌខ្ញុំ! ខ្ញុំបាត់ស្បែកជើង ពាក់អាវអ៊ីចឹងឱ្យខ្ញុំទៅរត់ម៉ារ៉ាតុង?!»

គេបែរមកថាឱ្យនាងខ្លីៈ

«មួយ!»

គេចាប់ផ្ដើមរាប់ហើយនាងក៏ស្លន់ស្លោចិត្តៈ

«ពីរ!»

ស្រីស្រស់ស្រែកចង់បង្អាក់គេយកពេលៈ

«ថារាប់ដល់១០ក្រោយខ្ញុំចេញសិនមែនអត់? នេះមិនទាន់បានរត់ផងណា៎!»

«បី!»

ស្រីសម្លក់ទឹកមុខហីរបស់គេ។ ភ្នែកនាងបញ្ចេញភាពខឹងសម្បារតវ៉ា តែក៏ចាប់ផ្ដើមសើយសំពត់ឡើងសម្លឹងទៅទ្វារ ហើយស្រវេស្រវារត់ចេញពីហ្វូងមនុស្សប្រុសទាំងអស់នោះ។ គ្រប់គ្នាក៏ថយមួយជំហានម្នាក់វែកផ្លូវទៅឱ្យនីយ៉ា។

ជើងនាងឈឺណាស់ វាគ្មានស្បែកជើងការពារផង នាងមិនស្គាល់ទីនេះផង ណាមួយចិត្តកំពុងខឹងប្រុសម្នាក់នោះយ៉ាងពុះពោរទៀត។

«កុំឱ្យខ្ញុំជួបមុខម្នាក់ហ្នឹងទៀតឱ្យសោះ!»

នាងថាព្រួៗកាត់តាមកម្លាំងវាយោរាត្រី។

នៅក្រោមពន្លឺរាត្រីដែលមិនអំណោយផល យប់រនោចគ្មានខែ គ្រប់យ៉ាងនឹងមិនអនុញ្ញាតឱ្យនាងកំណត់គោលដៅបានល្អភ្លាមទេ។

តាមវិធីផ្ទាល់ខ្លួនណាក៏ដោយ នាងចង់ចេញឱ្យឆ្ងាយកាន់តែល្អពីសំឡេងរាប់របស់គេ។

«៧.....៨»

«មនុស្សចង្រៃ!»

នាងរអ៊ូឡើងខណៈប្រឹងបន្តរត់យឺតយ៉ាវដោយជើងទទេឈឺសែនឈឺ ប៉ះតែពីលើបណ្ដាដុំគ្រួសនិងកូនថ្មក្រហម។ កន្លែងខ្លះមានភាពសើម និងលេចធ្លាយប្រភពទឹក។ នាងដឹងថា នេះជាកូនសំណង់នៅវាលទំនាបកណ្ដាលនៃកោះណាមួយ នាងកំពុងទាយឈ្មោះវា.....តែរូបរាងធម្មជាតិដ៏ងងឹតនិងកំណាចពេលនេះមិនបានរំឭកថានាងធ្លាប់ស្គាល់ទីនេះសោះឡើយ។

ដើមឈើដុះជាជួរងងឹតស្លុបនៅទិសខាងលិច។ សូម្បីតែមានភ្លើងហ្វាដែលហួសសម័យ តែមើលទៅគួរឱ្យញញើតពិតមែន។ ពីនេះមើលទៅសមុទ្រ មើលមិនឃើញសោះ ងងឹតពេក តែសន្ទឹកខ្យល់បញ្ជាក់ថា ឆ្នេរនៅមិនឆ្ងាយឡើយ។

ការរត់តាមកន្លែងមានពន្លឺជាជម្រើសល្អសម្រាប់នាងព្រោះនាងមិនស្គាល់ទីនេះ ចំណែកការពួនលាក់ខ្លួនក្នុងភាពងងឹត មុននឹងក្រោយគេគង់តែចុចពិលរកឃើញ។

ស្រីរត់សំដៅរុក្ខាវិថីដែលនាំមុខដោយថ្មភ្នំមួយដុំធំ កម្ពស់ត្រឹមចង្កេះមនុស្សចាស់។ ជើងនាងជាន់ប៉ះខ្សាច់ខ្លះ និងគ្រួសកំណាចខ្លះសែនឈឺ។

ស្នូរមោត់មនុស្សរត់មកតាមពីក្រោយលាន់រសាត់ព្រោះខ្យល់នាំមក ការនេះបង្កើនគំនិតស្លន់ឱ្យនាងប្រឹងរកកម្លាំងមកបន្ថែមល្បឿន។

«បើឱ្យចាប់បានវិញ លើកទីមួយ នឹងត្រូវអត់បាយក្របហាយទឹក បីថ្ងៃ បីយប់!»

សំឡេងបិសាចគួរឱ្យស្អប់លេចឡើងមកវិញក្នុងការចងចាំរបស់នាង។

«យើងខុសអីបានជាហ៊ានទុកយើងបីយប់បីថ្ងៃមនុស្សតិរច្ឆាន!»

នាងគិតទាំងចង់តែស្រែកតវ៉ាឱ្យបានខ្ទរខ្ទារមេឃ តែនីយ៉ាអស់ពេលហើយ។ រត់ទៅមុខទើបជាជម្រើសរបស់នាង។

ការទៅរកផ្លូវជាតិឬភូមិដ្ឋានអ្នកស្រុកទើបជាជម្រើសល្អ។ ពេលនោះខ្ញុំនឹងទាក់ទងទៅរកបងប្រុសខ្ញុំ។ នាងគិតទាំងសេចក្តីសង្ឃឹមក្នុងការចិញ្ចឹមចិត្តសងសឹកចាប់ផ្តើមសន្ធោរឆេះឡើង។

ប៉ុន្តែនៅពេលនោះ នៅពេលដែលនាងមើលមុតៗឡើងលើច្រាំង ពីមុខផ្លូវក៏បានឃើញពីចម្ងាយនូវភ្លើងហ្វាថ្មី.....វាជាភ្លើងឡាន.....ជិតឡើងៗ

«ល្អហើយ! យើងនឹងបានសុំគេដោយសារជិះទៅវិញភ្លាម!»

នាងរត់សំដៅទៅប្រសប់នឹងភ្លើងឡាន។

មនុស្សម្នាក់អង្គុយនៅទីនោះពេលនាងពាំងផ្លូវ។ ឡានគេឈប់ នាងហត់ណាស់ សឹងដាច់ខ្យល់ទៅហើយ។

«ឈប់សិន!»

នាងនិយាយដោយហត់ណាស់ និយាយមិនចង់ចេញទេ។

ឡានឈប់មែនដោយមិនចាំបាច់ឮនាងប្រាប់.....

ពីនេះទៅ ខំប្រឆាំងនឹងហ្វា នាងឃើញរាងអ្នកបើក ខ្ពស់ ហើយមានតែម្នាក់។

គេបើកទ្វារចុះមក ហើយដើរមករកនាងដោយមិនចាំបាច់បិទទ្វារឡានវិញ....

«យូរហើយ រត់បានត្រឹមហ្នឹង?»

គឺសំឡេងមនុស្សដែលនាងអស់ពាក្យដៀល។ គេបើកឡានវាងមកស្កាត់ចាប់នាងដែលរត់សស្លើតទាំងគ្មានទ្រនាប់ជើង?

នេះហ្អីប្រកួតយុត្តិធម៌?

«ក្មេងទំនើងបាតសង្គម ក៏មិនធ្វើថោកអ៊ីចឹងដែរ!»

នាងហាត់មែន សឹងអស់ដង្ហើមដក តែក៏នៅជេរចេញនៅឡើយ។

«មែន?»

ភាពខុសគ្នារវាងនាងនិងអ្នកដទៃ គឺរាល់ពាក្យជេររបស់នាង ដុតតន្ត្រាឱ្យចង់តែលេងបន្តនិងធ្ងន់ៗឡើង។ ឧក្រិដ្ឋកម្មដែលគេអាចធ្វើចំពោះសត្រូវរបស់គេកន្លងមក មិនបាច់វែងអន្លាយដូចជាមួយសត្រូវអារវសម្នាក់នេះទេ តែញ៉ាំងឱ្យនាងវេទនាម្តងបន្តិចៗ ក៏ល្អបានកម្សាន្តចិត្ត មិនអ៊ីចឹង?

ប្រុសគិតទាំងញញឹម សម្លឹងនាងដែលឈរស្កុប។

«ដែលអត់បាយបានបីថ្ងៃទេប្អូនប៉ូលិស?»

ឈាមរបស់នីយ៉ាឡើងកម្តៅរត់ពេញសរសៃសសូងដោយក្តីខឹងសម្បា។

«លោកឯងជិះឡាន ខ្ញុំរត់ដោយជើង មនុស្សអីអន់ម្ល៉េះ?»

គេឱនមករកគន្លាក់ជើងនាងហើយលើកស្រីលីលើស្មា ទៅរកឃ្លុបឡានគេ។

សូម្បីកៅអីក៏នាងគ្មានសិទ្ធិអង្គុយផង។ ប្រុសចម្លែកចុចបើកឃ្លុបហើយទម្លាក់នាងចូលព្រួស.... ឈឺណាស់!

ជួរជាតិពេកហើយ។

នាងស្រែកទាំងឈឺចាប់និងបិទភ្នែករំងាប់ព័ត៌មានឈឺចាប់ដែលបញ្ជូនមកសសៃប្រសាទ។

ទឹកមុខគេនៅនឹងមាត់ច្រកឡាន។ គេសម្លឹងនាងដោយកែវភ្នែកភ្លឺមុត អមដោយទឹកមុខស្មើៗញឹមៗ។

មិនមែនជាលើកទីមួយទេ ដែលនាងមើលគេដោយចងកំហឹង។